# អនុស្សរណៈនៃការយោគយល់គ្នារវាង

## ក្រសួងកិច្ចការនារី

## និង

## អង្គការផេកកម្ពុជា

## ស្តីពី

## ភាពជាដៃគូលើការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីកម្ពុជា

ខែ..៦..... ឆ្នាំ២០២២

# អនុស្សរណៈនៃការយោគយល់គ្នា

អនុស្សរណៈនៃការយោគយល់នេះ រៀបចំឡើងក្នុងខែ....... ឆ្នាំ២០២២ នៅរាជធានីភ្នំពេញរវាង **ក្រសួងកិច្ចការនារី** ដែលមានទីតាំងនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។

**និង**

**ផេកកម្ពុជា** (Pact Cambodia) ជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ដែលមានទីស្នាក់ការ នៅសហរដ្ឋអាមេរិក និងការិយាល័យក្នុងប្រទេសកម្ពុជានៅរាជធានីភ្នំពេញ(ដែលពីពេលនេះទៅហៅថា"ផេក")។ ផេក ជាអង្គភាពដែលបានចុះអនុស្សរណៈនៃការយោគយល់ជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដែលតំណាងដោយ លោកស្រី **សាប៊ីន យៅគ្គីស** នាយិកាប្រចាំប្រទេសរបស់អង្គការផេកកម្ពុជា សញ្ជាតិ ប៊ែលហ្ស៊ិក កាន់ប៉ាស្ព័រលេខ EN986743 ស្ថិតនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ ក្រសួងកិច្ចការនារី (MoWA) និងអង្គការផេកកម្ពុជា ចាប់ពីពេលនេះតទៅហៅថាជា "ភាគី" និងហៅជារួមថា "គូភាគី"។

## ប្រការ ១. គោលបំណង

គោលបំណងរបស់អនុស្សរណៈនៃការយោគយល់នេះ បង្កើតឡើងក្នុងការរៀបចំក្របខណ្ឌទូទៅជាផ្លូវការមួយសម្រាប់ទំនាក់ទំនងសហប្រតិបត្តិការ និងអនុវត្តសកម្មភាពរវាង ក្រសួងកិច្ចការនារី និងអង្គការផេក ក្នុងការប្តេជ្ញានិងពង្រឹងកិច្ចសហការទ្វេភាគីក្នុងការលើកកម្ពស់ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងពង្រឹងការបញ្ជ្រាបយេនឌ័រនៅកម្ពុជា ព្រមទាំងចូលរួមបង្កើនសក្តានុពលស្ត្រីក្នុងវិស័យសេដ្ឋកិច្ច ជាពិសេសក្នុងបរិបទនៃការរៀបចំដំណើរឆ្ពោះទៅសេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្មជំនាន់ទីបួន **(IR 4.0)** ស្របទៅនឹងផែនការយុទ្ធសាស្ត្រ"នារីរតនៈទី៥ ២០១៩-២០២៣" និងផែនការយុទ្ធសាស្ត្របន្តរបស់ក្រសួងកិច្ចការនារី។

## ប្រការ ២. ក្របខណ្ឌទូទៅ

អនុស្សរណៈនេះមិនពាក់ព័ន្ធនឹងកាតព្វកិច្ចក្នុងការផ្តល់ការគាំទ្រហិរញ្ញវត្ថុ ឬធនធានដល់ភាគីណាមួយឡើយ។ ប្រសិនបើកិច្ចសហការនេះមានតម្រូវការឲ្យជួយគាំទ្រផ្នែកធនធានហិរញ្ញវត្ថុ ឬលើការចំណាយណាមួយដែលនឹងត្រូវកើតឡើងអំឡុងពេលអនុវត្តនៃអនុស្សរណៈនេះ ភាគីទាំងពីរនឹងយល់ព្រម ក្នុងកិច្ចព្រមព្រៀងដាច់ដោយឡែក លើការគាំទ្រដូចជាហិរញ្ញវត្ថុ ការចំណាយផ្សេងៗ ឬក៏ធនធានជាមុន។

ក្របខណ្ឌទូទៅសម្រាប់ទំនាក់ទំនងសហប្រតិបត្តិការ និងសកម្មភាពរួមមានដូចតទៅ៖

២.១ សហការលើការពង្រីកកាលានុវត្តភាព និងបង្កបរិយាកាសអំណោយផលសម្រាប់អាជីវកម្មទាំងឡាយដែលគ្រប់គ្រងដោយស្ត្រីប្រកបដោយបរិយាបន្ន និងសហគ្រិនភាពប្រកបដោយនវានុវត្តន៍។

២.២ សហការលើការគាំទ្រនានាដល់ស្ត្រីឲ្យទទួលបាននូវកម្មវិធីជំនាញវិជ្ជាជីវៈ ដែលស្របទៅនឹងតម្រូវការនៃសេដ្ឋកិច្ចឌីជីថល និងប្រកបដោយបរិយាបន្ន ដូចជា៖ ជំនាញនៃការអភិវឌ្ឍអាជីវកម្ម សហគ្រិនភាព និងទីផ្សារឌីជីថលជាដើម ដោយផ្អែកតាមតម្រូវការរបស់ស្ត្រី។

២.៣ លើកកម្ពស់ការយកចិត្តទុកដាក់ និងការគាំទ្រដល់សកម្មភាពរបស់ស្ត្រីដែលពាក់ព័ន្ធនឹងការអភិវឌ្ឍអាជីវកម្មខ្នាតមីក្រូ និងតូច ជាពិសេសអាជីវកម្មក្រៅផ្លូវប្រព័ន្ធ។

២.៤ ការគាំទ្រសកម្មភាពដែលមានសក្តានុពលផ្សេងៗទៀត សម្រាប់គម្រោងនាពេលអនាគតសម្រាប់ស្ត្រី។

២.៥ ក្រសួង ឬអង្គការផេកកម្ពុជា មានសិទ្ធិស្នើបញ្ឈប់សកម្មភាពនៃអនុស្សរណៈនៃការយោគយល់គ្នានេះ ក្រោយពីបានពិភាក្សា និងមានការព្រមព្រៀងរវាងភាគីទាំងពីរ ប្រសិនបើពិនិត្យឃើញថាពុំមាន កិច្ចសហប្រតិបត្តិការគ្រប់គ្រាន់ សម្រាប់ការអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព ឬសន្តិសុខនៃបុគ្គលិក។

២.៦ ក្រសួងកិច្ចការនារី នឹងស្នើឱ្យអង្គការបញ្ឈប់សកម្មភាពការងារបុគ្គលិកដែលស្ថិតក្នុងក្របខណ្ឌអនុស្សរណៈ ដែលត្រូវបានគេវិនិច្ឆ័យថាធ្វើឱ្យខូចកិត្តិយសក្រសួង បានប្រព្រឹត្តខុសនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

២.៧ វិសោធនកម្មជាលាយលក្ខណ៍អក្សរនៃអនុស្សរណៈនេះ នឹងត្រូវធ្វើឡើងដោយមានការព្រមព្រៀងទៅវិញទៅមក និងចុះហត្ថលេខាដោយភាគីទាំងពីរបន្ទាប់ពីបានពិចារណារួចហើយ ។

២.៨ ក្នុងករណីរកឃើញថាអង្គការផេកកម្ពុជា មិនគោរពតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងកិច្ចការនារីអាចបញ្ឈប់អនុស្សរណៈនៃការយោគយល់គ្នានេះជាឯកតោភាគី បន្ទាប់ពីជូនព័ត៌មានដល់សាមីអង្គការនោះរួចមក។

## ប្រការ ៣. ការចូលរួមចំណែករបស់អង្គការផេក

អង្គការផេកនឹងសហការជាមួយក្រសួងកិច្ចការនារី និង/ឬ អង្គភាពពាក់ព័ន្ធផ្សេងទៀត ក្នុងការលើកកម្ពស់អំណាចសេដ្ឋកិច្ចរបស់ស្ត្រី ក្នុងការរៀបចំសកម្មភាពដូចតទៅ៖



SHD . 35 b OK

៣.១ គាំទ្រដល់យុទ្ធនាការ និងវេទិកាសាធារណៈ ដែលពាក់ព័ន្ធ (relevant public forum and campaign) ដើម្បីចែករំលែកបទពិសោធន៍ និងការជំរុញទឹកចិត្តលើភាពជាអ្នកដឹកនាំ និងដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីរវាងអ្នកជំនាន់មុន ពេលបច្ចុប្បន្ន និងអនាគត។

៣.២ លើកកម្ពស់ការយល់ដឹង និងស្វែងរកការគាំទ្រចំពោះបញ្ហាប្រឈម និងតម្រូវការសំខាន់ៗរបស់ស្ត្រីដែលមានសហគ្រាស ឬអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម ក្នុងកិច្ចសន្ទនា និងគោលនយោបាយថ្នាក់ជាតិដើម្បីឆ្លើយតបទៅនឹងបរិបទនៃសកលភាវូបនីយកម្ម សេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្មជំនាន់ទីបួន (IR 4.0)។ ជាឧទាហរណ៍ គាំទ្រលើចំណេះដឹងផ្នែកឌីជីថល និងជំនាញទីផ្សារឌីជីថល ដល់ស្ត្រីដែលជ្រើសរើសដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីប្រចាំខេត្ត។

៣.៣ បញ្ជ្រាបការគាំទ្រ កិច្ចសន្ទនាគោលនយោបាយពាក់ព័ន្ធការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ និងស្ត្រីក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ចូលទៅក្នុងរបៀបវារៈគោលនយោបាយ និងកិច្ចអន្តរាគមន៍។ ជាឧទាហរណ៍ កិច្ចសន្ទនាក្នុងន័យស្ថាបនាស្តីពី ការបង្ហាញសេចក្តីសង្ខេបពីគោលនយោបាយលើតម្រូវការធំៗរបស់ស្ត្រីក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ (អ្នកលក់ដូរតាមដងផ្លូវ) និងអនុសាសន៍សម្រាប់ការឆ្លើយតប និងកិច្ចអន្តរាគម៍គោលនយោបាយ។

៣.៤ ចូលរួមឱ្យបានទៀងទាត់នៅរាល់កិច្ចប្រជុំនានា ឬការប្រជុំក្នុងករណីចាំបាច់តាមការអញ្ជើញរបស់ក្រសួងកិច្ចការនារី ដើម្បីសម្របសម្រួលសកម្មភាពរបស់គម្រោង ព្រមទាំងធ្វើការផ្លាស់ប្តូរព័ត៌មានគ្នា ដើម្បីឈានទៅសម្រេចជោគជ័យតាមគោលដៅរបស់គម្រោង។

៣.៥ ផ្តល់ជូនក្រសួងកិច្ចការនារី នូវរបាយការណ៍ និងឯកសារពាក់ព័ន្ធរួមមាន៖

- របាយការណ៍សកម្មភាពអនុវត្តគម្រោង ប្រចាំត្រីមាស ឆមាស និង ប្រចាំឆ្នាំ
- ឯកសារនានាដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោង
- ព័ត៌មានអំពីចំនួនបុគ្គលិកអង្គការផេកកម្ពុជា ព្រមទាំងតួនាទីរបស់បុគ្គលិក

៣.៦ អង្គការផេកកម្ពុជានឹងជម្រាបជូនក្រសួងកិច្ចការនារី ជាលាយលក្ខណ៍អក្សរនៅពេលដែលមានការផ្លាស់ប្តូរអាសយដ្ឋាន លេខទូរស័ព្ទ អ្នកតំណាង ឬប្រធានកម្មវិធី ។

៣.៧ ផ្តល់ជូនផែនការសកម្មភាពរួមរវាងអង្គការផេក និងក្រសួងកិច្ចការនារី ក្នុងរយៈពេលបីខែក្រោយបន្ទាប់ពីចុះអនុស្សរណៈរួច។ ក្នុងករណី បន្ទាប់ពីចុះអនុស្សរណៈបានរយៈពេលបីខែក្រោយ អង្គការនៅតែមិនទាន់បានរៀបចំផែនការសកម្មភាពរួមជាមួយក្រសួងកិច្ចការនារីរួចរាល់ ហើយមិនមានការជូនព័ត៌មានជាផ្លូវការ ដល់ក្រសួងកិច្ចការនារី នោះក្រសួងកិច្ចការនារីមានសិទ្ធិបញ្ឈប់អនុស្សរណៈនៃការយោគយល់គ្នាដោយឯកតោភាគី។

## ប្រការ ៤. ការចូលរួមចំណែករបស់ ក្រសួងកិច្ចការនារី

ក្រសួងកិច្ចការនារីនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការជេកកម្ពុជា ដោយរួមចំណែកក្នុងសកម្មភាពគម្រោង និងកិច្ចសហការមានជាអាទិ៍៖

៤.១ ចូលរួមជាវាគ្មិនតាមការអញ្ជើញក្នុងកិច្ចពិភាក្សា ក្នុងវេទិកាសាធារណៈនិងទិវាផ្សេងៗ ដែលរៀបចំឡើងដោយអង្គការជេកកម្ពុជា ក្នុងប្រធានបទផ្សេងៗពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីកម្ពុជា។

៤.២ ចូលរួមតាមការអញ្ជើញ ដើម្បីផ្តល់ការសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលនានា ដែលរៀបចំឡើងដោយអង្គការជេកកម្ពុជា ក្នុងទិសដៅលើកកម្ពស់ភាពជាអ្នកដឹកនាំ សមភាពយេនឌ័រ និង លើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីកម្ពុជា ។

៤.៣ ចូលរួមកិច្ចប្រជុំ និងពិភាក្សា ព្រមទាំងផ្តល់អនុសាសន៍ ក្នុងការរៀបចំផែនការអនុវត្តកម្មវិធី និងការវាយតម្លៃកម្មវិធីដែលអង្គការជេកសហការជាមួយក្រសួងកិច្ចការនារី ។

៤.៤ ក្រសួងកិច្ចការនារីតែងតាំងឱ្យនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងនាយកដ្ឋានអភិវឌ្ឍសេដ្ឋកិច្ច ជាអង្គភាពក្នុងការធ្វើទំនាក់ទំនង តាមដាន និងវាយតម្លៃលើអនុស្សរណៈនៃការយោគយល់គ្នានេះ និងសម្របសម្រួលក្នុងការរៀបចំ និងអនុវត្តគម្រោងដែលមានសក្តានុពលរួមគ្នា ។

## ប្រការ ៥. សុពលភាព និងការបញ្ចប់នៃអនុស្សរណៈ

អនុស្សរណៈនេះគឺមានប្រសិទ្ធភាពពីថ្ងៃទី១៣ ខែ៤ ឆ្នាំ២០២២ រហូតដល់ ថ្ងៃទី១៣ ខែ ៤....ឆ្នាំ ២០២៧ [ថ្ងៃផុតកំណត់]។

អនុស្សរណៈនេះនឹងបញ្ចប់ដោយស្វ័យប្រវត្តិតាមកាលបរិច្ឆេទដែលបានកំណត់ និងអាចពិនិត្យព្រមព្រៀង និងបន្តជាថ្មីជាលាយលក្ខណ៍អក្សរដោយភាគីទាំងពីរ។

ភាគីមួយអាចបញ្ចប់ការចូលរួមក្នុងអនុស្សរណៈនេះក្នុងហេតុផលណាមួយ ដោយផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃទៅកាន់ភាគីម្ខាងទៀត។

## ប្រការ ៦. ការគោរពគ្នាទៅវិញទៅមក និងការរក្សាការសម្ងាត់

ភាគីនីមួយៗ ត្រូវរក្សាការសម្ងាត់នូវរាល់ព័ត៌មាននានា ទោះជាផ្ទាល់មាត់ លាយលក្ខណ៍អក្សរ ក្រាហ្វិក ឯកសារ និងទិន្នន័យផ្សេងៗ ទោះក្នុងទម្រង់អេឡិកត្រូនិក ឬតាមទម្រង់ណាមួយ (ហៅថា

«ព័ត៌មានសម្ងាត់») ដែលទទួលបាន ឬផ្តល់ជូនពីភាគី ក្នុងអំឡុងពេលអនុវត្តអនុស្សរណៈនេះ។ ប្រការនេះ ត្រូវមានសុពលភាពអនុវត្តទាំងក្នុងពេលមានសុពលភាពនិងអស់សុពលភាព នៃអនុស្សរណៈនេះ។

## ប្រការ ៧. ការយោគយល់គ្នាទៅវិញទៅមក និងការអនុវត្តន៍

ភាគីទាំងពីរត្រូវមានសេចក្តីស្មោះត្រង់ និងការខិតខំប្រឹងប្រែងអនុវត្តរាល់គោលការណ៍ដែលជាកាតព្វកិច្ចក្នុងអនុស្សរណៈនេះ ក៏ប៉ុន្តែមិនអាចប្រើផ្លូវច្បាប់ណាមួយប្រឆាំងនឹងភាគីមួយទៀតដែលបណ្តាលមកពីបទចោទប្រកាន់ណាមួយ ឬការលុបចោលដោយភាគីណាមួយ។

## ប្រការ ៨. ការដោះស្រាយជម្លោះ

ក្នុងព្រឹត្តិការណ៍នៃការកើតមានជម្លោះណាមួយលើអនុស្សរណៈនេះ គ្រប់ភាគីត្រូវប្រឹងប្រែងដោះស្រាយវិវាទដោយមិត្តភាព រួមទាំងការផ្តួចផ្តើមការចរចារដោយផ្ទាល់ជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ អ្នកតំណាង ឬការចរចាតាមរយៈអន្តរការី។

## ប្រការ ៩. ទំនាក់ទំនង

រាល់ទំនាក់ទំនងដែលពាក់ព័ន្ធជាមួយអនុស្សរណៈនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរ និងរួមបញ្ចូលអ៊ីម៉េល និងតេឡេក្រាម ដែលធ្វើឡើងក្នុងទម្រង់ផ្លូវការ។

## ប្រការ ១០. ផ្សេងៗ

បញ្ហា (ដូចជាលក្ខខណ្ឌនៃកិច្ចសន្យា) ដែលមិនរួមបញ្ចូលក្នុងអនុស្សរណៈនេះ ត្រូវបានកំណត់ក្នុងការចរចា និងកិច្ចព្រមព្រៀងដាច់ដោយឡែករវាងគូភាគី ។



SS OK

អនុស្សរណៈនេះត្រូវបានធ្វើឡើងជាពីរភាសា ភាសាខ្មែរ និងភាសាអង់គ្លេស ចំនួនពីរ (២)ច្បាប់ ។ អនុស្សរណៈនេះនឹងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

pact building local promise.

អង្គការផេកកម្ពុជា

Sabine Joukes

នាយិកាប្រចាំប្រទេស

ភ្នំពេញ កម្ពុជា

ក្រសួងកិច្ចការនារី

ចិន ស៊ុវីយ៍

រដ្ឋលេខាធិការ

ភ្នំពេញ កម្ពុជា

==================================================================

ព័ត៌មានសម្រាប់ទំនាក់ទំនង,

ផេកកម្ពុជា

អាសយដ្ឋាន:

ភ្នំពេញសេនធើរ, អាគារ F, ជាន់ទី 5, ផ្លូវសុធារស (3), កែងជ្រុង ផ្លូវព្រះសីហនុ (St. 274), ភ្នំពេញ កម្ពុជា

ព័ត៌មានសម្រាប់ទំនាក់ទំនង,

ក្រសួងកិច្ចការនារី

អាសយដ្ឋាន:

តាមបណ្តោយផ្លូវទ្រេង់មាន់ ភូមិ ជំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ

ភ្នំពេញ កម្ពុជា

ទំនាក់ទំនងពាក់ព័ន្ធនឹងការអនុវត្តគម្រោង៖

លោកស្រី សាប៊ីន យៅគ៉ឹស

នាយិកាប្រចាំប្រទេស

+855-12-406842,
sjoukes@pactworld.org

លោកស្រី សារ គឹមសឿន

អគ្គនាយករងនៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍសេដ្ឋកិច្ច

+855 11 606 627

លោក ខេង យុនទី
នាយកផ្នែក និងហិរញ្ញវត្ថុ
+855-12-833-100
KKheng@pactworld.org

លោកស្រី ប៉េង ឡូឌី
អនុប្រធានគម្រោង
+855-77-677122
plody@pactworld.org

ទំនាក់ទំនងពាក់ព័ន្ធនឹងដំណើរការនៃការចុះអនុស្សរណៈ:

លោក ទេព ដារាបញ្ញា
ប្រធានការិយាល័យ
+855 17 485 890, tep.darapanha97@gmail.com